ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
ចូលមក តាមរដ្ឋាននិតិកម្ម
ថ្ងៃទី23 ខែ11 ឆ្នាំ2023 ម៉ោង14:38
ចុះបញ្ជីលេខ 411

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៣០ អនក្រ.បក

ក្រសួងសុខាភិបាល
ចូលមក នាយកដ្ឋានរដ្ឋបាល
ថ្ងៃទី 20 ខែ 11 ឆ្នាំ2023 ម៉ោង 9:38
ចុះបញ្ជីលេខ 0573

មជ្ឈមណ្ឌលជាតិសុខភាពមាតា
ចូល លេខ ៣៤៧
មកដល់ថ្ងៃ ១៧.១០.២៣
ម៉ោង

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសុខាភិបាលឌីជីថល ចំណុះអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាលនៃក្រសួងសុខាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សម្រេច

**មាត្រា១ .-**

ត្រូវបានបង្កើតនាយកដ្ឋានសុខាភិបាលឌីជីថល ចំណុះអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាលនៃក្រសួងសុខាភិបាល។

**មាត្រា២.-**

នាយកដ្ឋានសុខាភិបាលឌីជីថល មានតួនាទីជាសេនាធិការឱ្យអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល នៃក្រសួងសុខាភិបាល និងមានភារកិច្ចដូចតទៅ៖

- ដឹកនាំ គ្រប់គ្រង អភិវឌ្ឍ នវានុវត្តន៍ និងអភិបាលកិច្ចសុខាភិបាលឌីជីថល
- រៀបចំនិងពង្រឹងការអនុវត្តគោលនយោបាយ ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត យុទ្ធសាស្ត្រ និងផែនការសុខាភិបាលឌីជីថល រួមទាំងប្រព័ន្ធអេកូសុខាភិបាលឌីជីថល ប្រព័ន្ធព័ត៌មាននិង/ឬ ទិន្នន័យសុខាភិបាល និងសន្តិសុខសាយប័រសុខាភិបាល
- រៀបចំនិងពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញានៃបច្ចេកវិទ្យាសុខាភិបាល និងផលិតផលសុខាភិបាលឌីជីថល
- គ្រប់គ្រងការបង្កើត-ការផ្ទេរ ការប្រើប្រាស់ និងការធ្វើអាជីវកម្មបច្ចេកវិទ្យាសុខាភិបាល និងផលិតផលសុខាភិបាលឌីជីថល រួមទាំងការផ្ដល់ ការកែប្រែ ការព្យួរ ការផ្ទេរ ឬការដកហូតអាជ្ញាបណ្ណឬវិញ្ញាបនបត្រ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- វាយតម្លៃនិងកំណត់អាទិភាពលើហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលឌីជីថល និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និង/ឬបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានសមស្រប រាប់បញ្ចូលទាំងផ្នែករឹង ផ្នែកទន់ និងបណ្ដាញ ដើម្បីធានាប្រសិទ្ធភាពនៃការវិនិយោគ និងចីរភាពនៃកិច្ចដំណើរការប្រព័ន្ធ
- អភិវឌ្ឍនិងនវានុវត្តន៍លក្ខណៈសម្បត្តិ ស្តង់ដា សេវាកម្ម និងប្រព័ន្ធ សម្រាប់ប្រព័ន្ធអេកូសុខាភិបាលឌីជីថល
- ដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការវាយតម្លៃបច្ចេកវិទ្យាសុខាភិបាល ការស្រាវជ្រាវនិងអភិវឌ្ឍន៍ និងនវានុវត្តន៍សុខាភិបាលឌីជីថល
- គ្រប់គ្រងនិងសម្របសម្រួលផែនការ គម្រោង និង/ឬកម្មវិធីវិនិយោគ សម្រាប់ការអភិវឌ្ឍនិងនវានុវត្តន៍សុខាភិបាលឌីជីថល
- កសាងនិងអភិវឌ្ឍសមត្ថភាពធនធានមនុស្សលើជំនាញសុខាភិបាលឌីជីថល តាមរយៈការផ្ដល់សេចក្ដីណែនាំបច្ចេកទេសឬពិធីសារនានា ការបណ្ដុះបណ្ដាល និងអភិបាលកិច្ចគាំទ្រជាដើម ដល់អង្គភាពសុខាភិបាលនិងមូលដ្ឋានសុខាភិបាលគ្រប់លំដាប់ថ្នាក់
- លើកកម្ពស់កិច្ចសហការជាមួយក្រសួង ស្ថាប័ន អង្គភាព ដៃគូពាក់ព័ន្ធ និងវិស័យឯកជន ព្រមទាំងកិច្ចសហប្រតិបត្តិការក្នុងតំបន់និងអន្តរជាតិ ក្នុងការអភិវឌ្ឍសុខាភិបាលឌីជីថល
- រៀបចំផែនការនិងរបាយការណ៍សកម្មភាពការងាររបស់នាយកដ្ឋាន តាមកាលកំណត់របស់អគ្គនាយក
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីអគ្គនាយក។

**មាត្រា៣.-**

នាយកដ្ឋានសុខាភិបាលឌីជីថល ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានសុខាភិបាលឌីជីថល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៣ កើត ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ឈាង រ៉ា**

លេខ០០១៣.ស.នក

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម បញ្ជូនមក

គ្រប់អង្គភាពក្រោមឱវាទ ដើម្បីផ្សព្វផ្សាយនិងអនុវត្ត។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ**

**ជិន វិសាល**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ